# សមភាពនៃមនុស្សតាមទ្រឹស្តីព្រះពុទ្ធសាសនា

**ព្រះពុទ្ធសាសានាជាសាសនាដំបូង ដែលប្រដៅមនុស្សអោយឈប់ប្រមាថមើលងាយគ្នាព្រោះតែរឿង វណ្ណៈ ជាតិ ត្រកូល ដោយតាំង ចំណុចប្រសព្វនៅត្រង់ សីលធម៌។ បើទុកជានរណាកើតក្នុងត្រកូលខ្ពស់ ទាប មាន ក្រ ស ខ្មៅ យ៉ាងណាក៏ដោយក៏មិនយកជាប្រមាណបានឡើយ តែបើតាំងនៅក្នុងសីលធម៌ ទើបបានឈ្មោះថាជាអ្នកគួរសរសើរ គួរលើកតំកើង ។ ផ្ទុយទៅវិញ បើប្រព្រឹត្តល្មើសនឹងសីលធម៌ បើទុកណាជាកើតក្នុងត្រកូលដ៏ខ្ពង់ខ្ពស់ យ៉ាងណាក៏ដោយក៏ចាត់ទុកថាជាមនុស្សពាល មនុស្សថោកទាប ដែលគួរអោយតិះដៀល។**

មុននឹងលើកគោលធម៌ក្នុងព្រះពុទ្ធសាសនាដែលប្រដៅអោយមនុស្សឈប់ប្រកាន់វណ្ណៈ មកនិយាយ ខ្ញុំសូមនាំយករឿងរ៉ាវផ្សេងៗដែលមានមកក្នុងគម្ពីរព្រះពុទ្ធសាសនាមកបង្ហាញជាមុនសិន ទុកគ្រាន់ជាគ្រឿងប្រដាប់សំរាប់ពិចារណាថា ក្នុងប្រទេសឥណ្ឌាសម័យបុរាណ មានការប្រកាន់វណ្ណៈចាក់ឫសរឹងមាំនិងតឹងតែងកាចសាហាវប៉ុណ្ណា ? ដើម្បីអោយអស់លោកអ្នកអានបានគន់គិត ពិនិត្យរែកញែកបំបែកសេចក្តី ចូលទៅរកអត្ថន័យពិតប្រាកដ ដែលកំណត់ក្នុងប្រធានបទខាងលើ ។

**រឿងទី១** ជារឿងរបស់មនុស្សក្នុងត្រកូលចណ្ឌាល ដែលត្រូវគេប្រមាថមើលងាយនិងប្រទូសរ៉ាយរាងកាយដោយហេតុត្រឹមតែបង្ហាញខ្លួនអោយមនុស្សវណ្ណៈខ្ពស់បានឃើញ តែក្រោយមកគេត្រឡប់ជារកមធ្យោបាយយកឈ្នះគ្រួសារវណ្ណៈខ្ពស់នោះ ដោយវិធីបន្ទាមុតយកបន្លាជួស ដូចមានរឿងរ៉ាវតទៅនេះ

បុរសម្នាក់មានឈ្មោះថា មាតង្គៈ ជាមនុស្សមានរូបរាងអាក្រក់ អាស្រ័យនៅក្នុងខ្ទមដែលបិទបាំងដោយស្បែកសត្វ ក្រៅព្រះនគរ ។ បុរសនោះកើតក្នុងត្រកូលចណ្ឌាល គឺត្រកូលដែលមានឪពុកម្តាយ ឬបុព្វបុរសរបស់គេជាមនុស្សមានវណ្ណៈខុសគ្នា ដូចជា ក្នុងវណ្ណៈទាំង៤ គឺ ក្សត្រ ( អ្នកចម្បាំង) ព្រាហ្មណ៍ ( អ្នកពិធីកម្ម) វៃស្សៈ ( អ្នកជំនួញ) និង សូទ្រៈ ( កម្មករ) ។ អ្នកកើតក្នុងវណ្ណៈណាមួយ ហើយទៅនៅរួមរស់ជាប្តីប្រពន្ធជាមួយវណ្ណៈខុសគ្នា លើកលែងតែវណ្ណៈក្សត្រនឹងវណ្ណៈព្រាហ្មណ៍ ពេលដែលបុត្រធីតារបស់អ្នកទាំងពីរនោះកើតមក គេចាត់ទុកថាជាមនុស្សចណ្ឌាល ជាមនុស្សដែលគេប្រមាថកាតទាន មើលងាយមើលថោក ថែមទាំងចាត់ទុកថាជាមនុស្សចង្រៃឧត្បាតទៀតផង ។

ដោយហេតុតែខ្លួនកើតក្នុងត្រកូលចណ្ឌាលហ្នឹងហើយ ទើបមាតង្គៈមិនអាចប្រកបមុខរបរអ្វីបានឡើយ ក្រៅពីការដើរសុំទានគេ ។

ថ្ងៃមួយគឺជាថ្ងៃនក្ខត្តឫក្ស ដែលនឹងមានការជប់លៀងសប្បាយរីករាយដោយការផឹកសុរា ពួកអភិជនទាំងឡាយនាំគ្នាត្រៀមរៀបចំសុរា និង អាហារដឹកដាក់រទេះទៅជប់លៀងយ៉ាងអឹកធឹកគគ្រឹកគគ្រេង ។

មានធីតាសេដ្ឋីម្នាក់ឈ្មោះនាងទិដ្ឋមង្គលិកា នាងមានវណ្ណៈជាព្រាហ្មណ៍មហាល (ព្រាហ្មណ៍ដែលជាសេដ្ឋី) ជាតរុណីដ៏ក្មេងខ្ចីមានរូបឆោមសម្ផស្សល្អស្រស់ឆើតឆាយ ទើបតែចំរើនវ័យបាន១៥ឬ១៦ ឆ្នាំប៉ុណ្ណោះ។ នាងបានចាត់អោយគេរៀបចំរទេះផ្ទុកទៅដោយគ្រឿងបរិភោគផ្សេងៗ មានបង្អែមនិងចំអាបជាដើមដើម្បីទៅចូលរួមក្នុងពិធីនក្ខត្តឫក្សនោះ ។ តរុណីសេដ្ឋីធីតា បានឡើងទៅលើយានពាហនៈដែលទឹមដោយសេះសហែហមអបអរដោយបរិវារ ចេញដំណើរទៅកាន់ព្រះនគរ ។ ព្រមជាមួយគ្នានោះ ក៏មានអ្នកថែរក្សាការពារចាំដេញពួកជនដែលមានវណ្ណៈទាបមិនអោយចូលទៅជិតបរិវេណនោះទៀតផង ។

មាតង្គៈដែលជាមនុស្សចណ្ឌាលក៏កាន់ដំបងដែលមានលក្ខណៈស្រដៀងនឹងត្រដោក សំរាប់គោះអោយមានសំលេងឮឡើងពេលចូលទៅក្នុងទីប្រជុំជន។ ការគោះបន្លឺសំលេងនេះបានផលពីរយ៉ាងគឺ ជាការប្រកាសអោយជនទាំងឡាយដឹងថាកំពុងសុំទាន អ្នកមានចិត្តមេត្តាត្រាប្រណីក៏នឹងបានអោយទាន ម្យ៉ាងទៀត ជាការប្រាប់ដោយស្វ័យប្រវត្តិថា មនុស្សចណ្ឌាលមកហើយ អ្នកដែលប្រកាន់មាំតឹងរឹងក្នុងប្រពៃណីមិនចូលជិតមនុស្សចណ្ឌាលក៏នឹងបានចៀសចេញអោយឆ្ងាយ ឬមិនអាចបន្ទោសបានថា មិនប្រាប់ជាមុន។ តាមពិតប្រព័ន្ធសង្គមមនុស្សក្នុងសម័យនោះវាពិតជាដូច្នោះមែន គឺមនុស្សវណ្ណៈទាប តែងតែព្យាយាមគេចវេះ មិនចូលទៅជិតអ្នកមានវណ្ណៈខ្ពស់ ហើយក៏មិនចាប់កាន់អ្វីៗរបស់អ្នកដទៃដែរ ។

ក្នុងពេលដែលមាតង្គៈកំពុងដើរគោះកំណាត់ឈើឮសូរប៉ោកៗនោះ ស្រាប់តែក្បួនរទេះរបស់សេដ្ឋីធីតាឆ្លងកាត់មកដល់ទីនោះ ព្រមជាមួយនឹងពពួកភ្នាក់ងារដែលដើរដេញមនុស្សវណ្ណៈទាបអោយចៀសចេញឆ្ងាយ ជាហេតុចៃដន្យ ឬក៏ជាអកុសល ឬមួយក៏ជាកុសលផលកម្មលិខិតរបស់មាតង្គៈក៏មិនដឹង នាងទិដ្ឋមង្គលិកា បានក្រលេកទៅឃើញមាតង្គៈក៏សួរថា នោះជានរណា? លុះដឹងថាជាមនុស្សចណ្ឌាលទាំងរូបរាងក៏អាក្រក់អប្បលក្ខណ៍គួរខ្ពើមរអើមទៀតផង ផ្សំនឹងរឿងដែលនាងជាអ្នកប្រកាន់ជោគជតារាសីក្នុងរឿងដូច្នេះ គឺប្រកាន់ថាពេលដែលបានជួបមនុស្សចង្រៃឧត្បាតហើយ នឹងអាប់រាសី គ្មានសេចក្ដីចំរើនក្នុងជីវិត ។ នាងក៏បញ្ជាអោយ

ក្បួនរទេះត្រឡប់ក្រោយវិញ ដោយមិនទៅចូលរួមក្នុងពិធីជប់លៀងដូចដែលបានប៉ងទុកនោះទេ ហើយហៅអោយគេយកគន្ធវារីមកលាងភ្នែកដើម្បីបំបាត់ចង្រៃឧបទ្រពមួយរំពេច ។

ការវិលត្រឡប់របស់សេដ្ឋីធីតា ធ្វើអោយមនុស្សជាច្រើនមានការខកចិត្តជាខ្លាំង ព្រោះគិតថា នឹងបានផឹកស្រា ទទួលទានអាហារមានរសឆ្ងាញ់ដោយមិនបាច់ចំណាយលុយកាក់ ។ ដោយម្ចាស់កម្មវិធីត្រឡប់ទៅវិញដូច្នេះ នក្ខត្តឫកទាំងមូលដូចជាគ្មានន័យអ្វីសំរាប់ពួកគេទាល់តែសោះ ។ ហេតុនេះហើយ ពួកអ្នកទាំងនោះក៏ខឹងសម្បារនឹងមាតង្គៈយ៉ាងខ្លាំង នាំគ្នាយកដុំដីគប់រហូតដល់ដួលសន្លប់បាត់ស្មារតី ។ ឃើញមាតង្គៈសន្លប់បាត់ស្មារតីដូច្នោះ អ្នកទាំងនោះនឹកស្មានថាស្លាប់ក៏នាំគ្នាសែងបុរសកំសត់នោះទៅចោលក្នុងគំនរសំរាម ហើយយកសំរាមកប់ពីលើ ។

ពេលដែលមានស្មារតីឡើងវិញ មាតង្គៈក៏បោសខ្លួនប្រាណ រលាស់ដៃជើងដើម្បីអោយបាត់ការសឺ មមឹង មមើង ។ មាណពនេះអង្គុយសញ្ជឹងគិតរំលឹកពីហេតុការណ៏ដែលកើតឡើង ក៏ចាំបានថា ខ្លួនត្រូវគេវាយធ្វើបាបព្រោះបង្ហាញមុខអោយធីតាសេដ្ឋីឃើញ ។ មាតង្គៈជាមនុស្សមានហេតុផល ជាមនុស្សម្នាក់មានម្ចាស់ការលើខ្លួនឯង គេគិតថា នឹងចាត់ការរឿងនេះអោយទាល់តែបាន ហើយអោយស័ក្តិសមនឹងអ្វីដែលខ្លួនត្រូវគេធ្វើបាបប្រមាថមើលងាយដោយគ្មានហេតុផល ។ គិតដូច្នោះហើយ គេក៏ដើរត្រាច់សួរមនុស្សទាំងឡាយ ជាការសួរធ្វើពើរ ដើម្បីអោយមានហេតុផលឡើងក្នុងទីប្រជុំជនថា តើទ្វារនគរនេះធ្វើឡើងសំរាប់តែមនុស្សត្រកូលព្រាហ្មណ៏ ឬក៏ធ្វើសំរាប់មនុស្សទូទៅ? ចំឡើយរបស់មហាជនទាំងឡាយឆ្លើយឡើងស្របគ្នាថា ធ្វើឡើងសំរាប់មនុស្សទូទៅ ។

ពេលដែលបានចំលើយយ៉ាងនេះហើយ មាតង្គៈក៏ប្រកាសឡើងភ្លាមថា ខ្ញុំមកសុំទានឆ្លងកាត់តាមទ្វារនគរដែលកសាងឡើងសំរាប់មនុស្សគ្រប់គ្នាដើរចេញចូល តែខ្ញុំត្រូវគេប្រទូសរ៉ាយរាងកាយ ដោយហេតុគ្រាន់តែសេដ្ឋីធីតាបានឃើញខ្ញុំហើយមានការស្អប់ខ្ពើម ចាប់ពីពេលនេះទៅ សូមមហាជនទាំងឡាយជ្រាបថា ខ្ញុំនឹងទៅដេកពាំងខ្លោងទ្វារផ្ទះសេដ្ឋីដែលជាបិតារបស់នាងទិដ្ឋមង្គលិកា បើមិនបាននាងនោះមកជាភរិយាទេ ខ្ញុំនឹងមិនក្រោកចាកទីនោះឡើយ ។

រឿងដែលមាតង្គៈសំរេចចិត្តធ្វើយ៉ាងនេះ ក៏ព្រោះតែមានប្រពៃណីមួយប្រកាន់ថា បើមនុស្សចណ្ឌាលមកដេកស្លាប់នៅនឹងខ្លោងទ្វារផ្ទះរបស់នរណាដោយតាំងចិត្តអត់បាយអត់ទឹកអោយស្លាប់ អ្នកដែលនៅក្នុងផ្ទះ

បរិវេណនោះ រាប់ចាប់ពីផ្ទះនោះទៅដោយជុំវិញ ៧ ផ្ទះ នឹងត្រូវក្លាយជាមនុស្សចណ្ឌាលទាំងអស់គ្នា ។ មាតង្គៈប្រើវិធីនេះ ក៏ព្រោះតែចង់អោយមនុស្សដែលរស់នៅក្នុងបរិវេណនោះ គ្រប់ទិសដែលមាន៧ផ្ទះ រាប់ចាប់ពីផ្ទះកណ្តាលគឺផ្ទះរបស់សេដ្ឋីទៅ ត្រូវជួបក្តីក្តៅក្រហាយទាំងអស់គ្នា ជាពិសេសគឺផ្ទះរបស់សេដ្ឋីដែលជាដើមរឿងផ្ទាល់មានក្តីក្តៅក្រហាយខ្ពល់ខ្វាយជាងគេបំផុត ។

ទីបំផុត សេដ្ឋីក៏សំរេចចិត្តបញ្ជាអោយអ្នកបំរើយកប្រាក់ទៅអោយមាតង្គៈជាថ្នូរទឹកចិត្ត ១កាកណិក[១] ដែលជាចំនួនតិចបំផុត ហើយអោយប្រាប់ថា នឹងអោយប្រេងលាបខ្លួនរួចសុំអោយចៀសចេញពីទីនោះ ។

ទំនៀមទំលាប់ប្រើប្រេងសំរាប់លាបជើងលាបខ្លួននោះ តាមឯកសារដែលនិយាយពីជីវភាពរស់នៅនៃជនជាតិឥណ្ឌាសម័យបុរាណ ពេលមានភ្ញៀវពន្លឺដែលធ្វើដំណើរផ្លូវឆ្ងាយមកលេងម្តងៗ ម្ចាស់ផ្ទះតែងតែយកប្រេងមកទទួលដើម្បីអោយលាបដៃជើងខ្លួនប្រាណ ។ ការប្រើប្រេងលាបនេះ មិនប្រាកដថាជាគ្រឿងតុបតែងកាយនោះទេ តែអាចជាថ្នាំជួយបន្ធូរបន្ថយការចុករោយស្រពន់ ឬជាគ្រឿងធ្វើអោយបានស្រលះមុខស្រលះមាត់ ចំពោះអ្នកដែលធ្លាប់ប្រើប្រាស់ក៏អាចថាបាន ។ សូម្បីព្រះភិក្ខុក្នុងព្រះពុទ្ធសាសនា ពេលនិមន្តផ្លូវឆ្ងាយក៏ប្រើប្រេងនេះដូចគ្នាដែរ ។

មាតង្គៈបដិសេធដាច់អហង្ការថា ទាល់តែបាននាងសេដ្ឋីធីតាមកធ្វើជាភរិយាទើបព្រមចាកចេញ ។ លោកសេដ្ឋីក៏បញ្ជាអោយគេថែមប្រាក់អោយទៅជាពីរកាកណិក រហូតដល់១មាសក[២] ហើយថែមឡើងរហូត ដល់ ៥មាសក ថែមតទៅទៀតដល់កន្លះកហាបណៈ[៣] បន្ថែមឡើងដល់ ១កហាបណៈ បន្ថែមទៀតដល់១០០ កហាបណៈ ។ រាត្រីកាលបានកន្លងទៅរហូតដល់អរុណជិតរះឡើង មាតង្គៈក៏នៅតែមិនព្រមផ្លាស់ប្តូរចិត្ត ។ លុះព្រឹកព្រាងស្វាងរស្មី ភរិយារបស់លោកសេដ្ឋីក៏មកអង្វរសុំទោស ហើយសុំថែមលុយអោយមាតង្គៈចំនួន ១០០០ កហាបណៈ បុរសចណ្ឌាលក៏នៅតែមិនព្រម បន្ថែមឡើងទៀតដល់មួយសែនកហាបណៈ ក៏នៅតែមិនព្រម គេនៅតែដេកនៅស្ងៀមដដែល ។ ពេលវេលាកន្លងទៅបាន ៤ថ្ងៃ មនុស្សក៏មកចោមរោមមើល ហើយនាំគ្នានិយាយតពីមាត់មួយទៅមាត់មួយរហូតក្លាយជាពតិមានដែលឮសាយសុះ ជារឿងស្លាប់រស់

---

១.ឈ្មោះប្រាក់ឥណ្ឌាសម័យបុរាណ ១កាកណិក តម្លៃស្មើដុំសាច់មួយដុំដែលក្អែកពាំរួច ២ ទំងន់ស្មើគ្រាប់សណ្តែករាជមាសមួយគ្រាប់

៣. ១កហាបណៈ = ប្រាក់ទំងន់ ៤ បាទ ១បាទ= ៦០ សេនប្រាក់សម័យបុរាណ

របស់មនុស្សជាច្រើនគ្រួសារដែលរស់នៅជិតផ្ទះរបស់ព្រាហ្មណ៍មហាសាលនោះ ។ ព្រោះកាលបើមាតង្គៈស្លាប់ទៅ មនុស្សក្នុងបរិវេណនោះនឹងក្លាយជាពួកចណ្ឌាលទាំងអស់ ដែលគេចាត់ទុកថាជាការបាត់បង់ដ៏ធំធេងបំផុតក្នុងជីវិត ។

បណ្ដាពួកអ្នកដែលទៅចោមរោមមើលនោះ អ្នកខ្លះក៏ជួយលើកទឹកចិត្តមាតង្គៈ ដោយខ្សិនខ្សឹបដាក់ត្រចៀកថា គេអត់ធន់រាប់ឆ្នាំនៅតែអាចសំរេចបំណងបាន អ្នកឯងទ្រាំអត់ធន់ត្រឹមតែ២-៣ ថ្ងៃទៀតទៅគង់នឹងអាចយកកូនសេដ្ឋីមកធ្វើជាភរិយាបានមិនខាន ។

លុះពេលវេលាកន្លងទៅបាន ៧ ថ្ងៃ ប្រជាជននៅក្នុងផ្ទះជិតខាងដែលសុទ្ធសឹងតែជាអ្នកកើតក្នុងត្រកូលព្រាហ្មណ៍ ក៏នាំគ្នាទៅបង្ខំសេដ្ឋីអោយព្រមប្រគល់ធីតាទៅមាតង្គៈ ព្រោះការរឹងត្អឹងរបស់សេដ្ឋី អាចធ្វើអោយពួកគេ បណ្ដោយធ្លោយធ្លាក់ទៅក្នុងវិបត្តិដ៏ធ្ងន់ធ្ងរនោះផងដែរ ។ លោកសេដ្ឋីទាល់គំនិតមិនដឹងជាគិតដូចម្ដេចក៏បង្ខំចិត្តលើកបុត្រីជាទីស្រលាញ់របស់ខ្លួនអោយទៅមាតង្គៈ ព្រមទាំងចែកទ្រព្យសម្បត្តិមួយចំនួនអោយចាកចេញពីផ្ទះទៅ ។ ទីបំផុត មាតង្គៈដែលជាមនុស្សចណ្ឌាលក៏បានទទួលជ័យជំនះលើមនុស្សវណ្ណៈព្រាហ្មណ៍ ហើយបានធីតាសេដ្ឋីទៅធ្វើជាភរិយា ។ រឿងរ៉ាវទាំងនេះ អាចធ្វើអោយអស់លោកអ្នកអានបានឃើញពីភាពច្របូកច្របល់ដែលកើតពីការប្រការវណ្ណៈនៃមនុស្សសម័យនោះបាន ។ **អដ្ឋកថា មាតង្គជាតក ភាគ៧**

**រឿងទី២** កើតឡើងចំពោះព្រះសម្មាសម្ពុទ្ធផ្ទាល់ គឺ ថ្ងៃមួយក្នុងរដូវរងាមានហិមៈធ្លាក់ ព្រះសម្ពុទ្ធទ្រង់យកចីវរគ្របព្រះកេសគង់ក្រោមដើមឈើមួយដើម ពេលនេះមានព្រាហ្មណ៍ម្នាក់ឈ្មោះសុន្ទរិកៈភារទ្វាជៈដើរចូលទៅជិតព្រះអង្គ ។ព្រះពុទ្ធអង្គទ្រង់ឮសូរីបជើងទើបទ្រង់ទំលាក់ចីវរដែលគ្របព្រះកេសចុះ ។ ព្រាហ្មណ៍សួរថា តើអ្នកជាមនុស្សកើតក្នុងជាតិអ្វី ត្រកូលអ្វី ហើយវណ្ណៈអ្វី? ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា "ចូរអ្នកកុំសួរពីជាតិកំណើត ត្រកូល វណ្ណៈធ្វើអ្វី ចូរសួរពីការប្រព្រឹត្តប្រតិបត្តិ នោះទើបជាការប្រសើរ" តាមពិតព្រះអង្គអាចឆ្លើយបានដោយមិនខ្លាចការប្រមាថមើលងាយថា ព្រះអង្គជាជាតិក្សត្រ ក៏ប៉ុន្តែដើម្បីជាការដាស់សតិដល់ព្រាហ្មណ៍អោយឃើញថា ការប្រព្រឹត្តរបស់មនុស្សមានសារៈសំខាន់ជាងជាតិ ត្រកូល ទើបព្រះអង្គទ្រង់ឆ្លើយដូច្នោះ ។ **សុត្តន្តបិដក សុន្ទរិកសូត្រ ភាគទី ១៥**

**រឿងទី៣** កើតឡើងចំពោះព្រះសម្មាសម្ពុទ្ធដដែល នៅក្នុងអម្ពដ្ឋសូត្រ ទីឃនិកាយ ភាគទី៩ មានសំដែងពីការរើសអើង ឡើងចាងពីរឿងវណ្ណៈរបស់ព្រាហ្មណ៍ម្នាក់ឈ្មោះអម្ពដ្ឋៈដែលទៅសួរព្រះសម្មាសម្ពុទ្ធ

ពីរឿងវណ្ណៈ ព្រះអង្គទ្រង់អាស្រ័យចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ត្រាស់តបព្រាហ្មណ៍នោះអោយដឹងថា ត្រកូលដើមរបស់គេគឺជាអ្នកបំរើរបស់ស្តេចសាក្យៈ ម្យ៉ាងវិញទៀត ក្នុងករណីដែលមាណពនោះប្រកាន់ថា ខ្លួនជាមនុស្សកើតក្នុងត្រកូលព្រាហ្មណ៍ ហើយមើលងាយអ្នកដែលកើតក្នុងត្រកូលផ្សេងៗនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បកស្រាយអោយស្តាប់ដោយហេតុផលថា ទាំងខ្សែខាងម្តាយ ឬខ្សែខាងឪពុក ទំនៀមទំលាប់ប្រពៃណីក៏នៅតែប្រកាន់ថា ក្សត្រគឺជាត្រកូលខ្ពង់ខ្ពស់ជាងគេ ។ មានសេចក្តីឧទាហរណ៍ដូចជា ខត្តិយកុមារ រៀបការជាមួយកុលធីតាក្នុងត្រកូលព្រាហ្មណ៍ ប្រសូតិបុត្រមក បុត្រនោះរមែងបានទទួលទីអង្គុយនិងទឹកផឹកក្នុងចំណោម ពួកព្រាហ្មណ៍ (ពួកព្រាហ្មណ៍នឹងស្វាគមន៍រាប់អាន) តែមិនបានអភិសេកជាក្សត្រទេ ព្រោះមិនទាន់បរិសុទ្ធ ខាងខ្សែមាតា។ កុលបុត្រត្រកូលព្រាហ្មណ៍ រៀបការជាមួយកុលធីតាត្រកូលក្សត្រ ប្រសូតិបុត្រមក បុត្រនោះរមែងបានទទួលទីអង្គុយនិងទឹកផឹកក្នុងចំណោមពួកព្រាហ្មណ៍ តែមិនបានអភិសេកជាក្សត្រទេ ព្រោះមិនទាន់បរិសុទ្ធខាងខ្សែបិតា ។ បានសេចក្តីថា បុត្រដែលកើតពីឪពុកម្តាយចំរុះវណ្ណៈគ្នារវាងក្សត្រនិងព្រាហ្មណ៍ អាចចូលក្នុងចំណោមពួកព្រាហ្មណ៍បាន ក៏ប៉ុន្តែអភិសេកជាក្សត្រមិនបានទេ ទាល់តែបរិសុទ្ធិក្នុងត្រកូលក្សត្រសុទ្ធសាធ ទើបអាចអភិសេកជាក្សត្របាន ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់សួរទៅព្រាហ្មណ៍ថា ព្រាហ្មណ៍ដែលត្រូវគេបំបរបង់ចេញពីពួកព្រាហ្មណ៍ ត្រូវគេកោរក្បាលផ្ចាលទោសហើយ តើអាចបានកន្លែងអង្គុយនិងទឹកផឹកអំពីពួកព្រាហ្មណ៍ដែរឬទេ? អម្ពដ្ឋមាណពឆ្លើយថា មិនបានទេ ។ ព្រះអង្គទ្រង់ត្រាស់សួរតទៅទៀតថា ក្សត្រដែលគេបំបរបង់ចេញពីពពួកក្សត្រត្រូវគេកោរក្បាលផ្ចាលទោសហើយ នឹងបានទទួលទីអង្គុយនិងទឹកផឹកពីពពួកព្រាហ្មណ៍ដែរឬទេ? អម្ពដ្ឋមាណពឆ្លើយថា បាន ។ ចំលើយនេះគឺជាការទទួលស្គាល់ថា តាមទំនៀមទំលាប់ប្រពៃណី ក្សត្រមិនត្រូវគេស្អប់ខ្ពើមដូចជាវណ្ណៈដទៃទេ ។ កាលដែលព្រះសម្មាសម្ពុទ្ធទ្រង់បកស្រាយបញ្ជាក់ពីហេតុផលក្នុងរឿងវណ្ណៈអោយមាណពនោះបានរំសាយទិដ្ឋិមានះហើយ ទើបទ្រង់សំដែងពីវិជ្ជាគឺការយល់ដឹងពីសច្ចធម៌ និង ចរណៈគឺការប្រព្រឹត្ត ដែលអាចធ្វើអោយបុគ្គលបាននូវភាពខ្ពង់ខ្ពស់និងថ្លៃថ្នូរ ដោយមិនបាច់ភ័យខ្លាចអាប់អោនក្នុងរឿង វណ្ណៈ ជាតិ ត្រកូល ហើយសេចក្តីនេះក៏ជាការរំលឹកអោយអម្ពដ្ឋព្រាហ្មណ៍ដឹងថា តើគេមានវិជ្ជានិងចរណៈនោះហើយឬនៅ ។ ព្រះអង្គទ្រង់បញ្ជាក់អោយមាណពនោះដឹងខ្លួនថា គ្រាដំបូងដំគេមានទិដ្ឋិក្អេងក្អាងក្នុងរឿងវណ្ណៈជាតិត្រកូល រហូតដល់ព្រះអង្គទ្រង់បកស្រាយអោយឃើញថា ការយល់ដឹងនូវសច្ចធម៌ និង ការប្រព្រឹត្តប្រតិបត្តិនោះមានសារៈសំខាន់ជាង ព្រោះថា ការប្រកាន់ខ្លួនរបស់មាណព

នោះ បើវែកញែកទៅតាមទំនៀមទំលាប់ប្រពៃណី ក៏នៅមានចំណុចខ្សោយ ដែលជាចំណុចអន់ជាងវណ្ណៈដទៃ ក្នុងករណីមួយចំនួន ។ សេចក្តីក្នុងព្រះសូត្រនេះ ធ្វើអោយបានជាសុភាសិតជាភាសាបាលីមួយបទថា:

**ខត្តិយោ សេដ្ឋោ ជនេតស្មឹ យេ គោត្តប្បដិសារិនោ**

**វិជ្ជាចរណសម្បន្នោ សោ សេដ្ឋោ ទេវមានុសេ្ស ។**

ប្រែថា: ក្នុងពួកមនុស្សដែលខ្វល់ខ្វាយក្នុងការប្រកាន់ជាតិត្រកូល ក្សត្រចាត់ទុកថាជាអ្នកប្រសើរបំផុត ប៉ុន្តែអ្នកដែលបរិបូណ៌ដោយចំណេះដឹង និង ការប្រព្រឹត្ត រមែងជាអ្នកប្រសើរបំផុត ក្នុងចំណោម ទេវតា និង មនុស្ស ។

សុភាសិតនេះព្រះពុទ្ធអង្គទ្រង់សំដែងថា តាមគន្លងប្រពៃណីក្នុងការប្រកាន់ជាតិ វណ្ណៈ ក្សត្រត្រូវគេចាត់ទុកថាជាវណ្ណៈខ្ពង់ខ្ពស់ ប៉ុន្តែបើនិយាយតាមគោលនៃសច្ចធម៌ មនុស្សដែលប្រកបដោយសុវិជ្ជា គឺមានចំណេះដឹងល្អនិង ការប្រព្រឹត្តដ៏ប្រពៃ រមែងជាអ្នកខ្ពង់ខ្ពស់ទាំងក្នុងពួកទេវតានិងមនុស្សទាំងឡាយ បានន័យថា បើទេវតាប្រព្រឹត្តមិនត្រឹមត្រូវតាមធម៌ ក៏មានគុណធម៌ទាបជាងមនុស្ស ។

**រឿងទី ៤** ជារឿងដែលទាក់ទងនឹងសាក្យវង្សដែលជាព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ គឺជារឿងស្លាប់រស់ប្រកបដោយគំនុំគុំគួនសងសឹកបង្ហូរឈាម ព្រោះតែមូលហេតុនៃការប្រមាថមើលងាយគ្នាពីរឿងវណ្ណៈ ។

មានសេចក្តីដំណាលក្នុងអដ្ឋកថាធម្មបទថា ព្រះបាទបសេនទិកោសល្យ មានអាណាខេត្តគ្រប់គ្រងគ្របដណ្តប់ទៅដល់ដែនកាសីនិងដែនសក្កៈ គឺដែនសក្កៈដែលមានរាជធានីឈ្មោះកបិលព័ស្តុនោះជាចំណុះរបស់ដែនកោសល្យ ។ ប៉ុន្តែតាមភស្តុតាងដែលមានក្នុងគម្ពីរព្រះបាលី មិនបានប្រាប់ថា ព្រះរាជាខាងកបិលព័ស្តុត្រូវបញ្ជូនសួយសាអាករ ឬត្រូវទទួលការគាបសង្កត់យ៉ាងណាខ្លះនោះទេ ។

ព្រះបាទបសេនទិកោសល្យមានសេចក្តីជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ និងស្និទ្ធស្នាលរហូតដល់ពេលខ្លះដែលព្រះអង្គចូលគាល់ព្រះសម្មាសម្ពុទ្ធ ទ្រង់ចាប់កព្រះបាទរបស់ព្រះដ៏មានព្រះភាគច្របាច់គក់ដោយសេចក្តីគោរពដ៏ស្មោះអស់ពីព្រះរាជហឫទ័យ ។ ប៉ុន្តែដើម្បីអោយកាន់តែស្និទ្ធស្នាលខ្លាំងឡើង ទើបទ្រង់បញ្ជូនទូតទៅកាន់ក្រុងកបិលពស្តុ ចូលស្តីដណ្តឹងព្រះរាជបុត្រីនៅក្នុងសាក្យវង្សមកអភិសេកដើម្បីអោយបានជាប់ ជាសាច់សាលោហិតកាន់តែជិតឡើង ដោយតាមប្រពៃណីប្រទេសឥណ្ឌាក្នុងបុរាណកាល ការមានមហេសីច្រើនចាត់ទុកថាជារឿងធម្មតារបស់ព្រះរាជា ។

ចំណែកព្រះរាជាខាងក្រុងកបិលព័ស្តុ ក្សត្រសាក្យវង្សដែលល្បីល្បាញខាងការប្រកាន់ពូជពង្សវណ្ណៈដ៏តឹងរឹងនោះ បានប្រជុំគ្នាប្រកបដោយចិត្តកង្វល់ ព្រោះមិនត្រូវការអោយរាជធីតាក្នុងវង្សរបស់ខ្លួន ទៅរួមរស់រួមត្រកូលជាមួយព្រះបាទបសេនទិកោសល្យ ដោយព្យាយាមរកដំណោះស្រាយដ៏ល្អជាទីបំផុត ។ មានសំនួរសួរថា បើមិនព្រមរួមត្រកូលជាមួយអ្នកដទៃទេ ស្តេចសាក្យៈនឹងធ្វើយ៉ាងណា? ឆ្លើយថា ស្តេចសាក្យវង្ស នឹងរៀបអភិសេកជាមួយសាច់ញាតិរបស់ខ្លួន ។ ម្យ៉ាងវិញទៀត ក្រៅពីការផ្សំផ្គុំរវាងសាច់ញាតិនៅក្នុងសាក្យត្រកូលរបស់ខ្លួន ក៏នៅមានរាជវង្សមួយទៀតដែលរៀបអភិសេកជាមួយនឹងសាក្យវង្ស គឺ កោលិយវង្ស ព្រះរាជាសាក្យវង្សទ្រង់មិនស្អប់ខ្ពើមវង្សនេះទេ ព្រោះកំណើតពង្សាវតារនៃវង្សទាំងពីរនេះ មានដើមកំណើតមកពីជេដ្ឋភគនីរបស់បងប្អូនបួនគូដែលមកតាំងវង្សនៅក្នុងក្រុងកបិលព័ស្តុ គឺបងប្អូនបង្កើតបួនគូរៀបការជាមួយគ្នាឯង ។ ចំណែកបងស្រីច្បងបានរៀបការជាមួយក្សត្រមួយអង្គទៀតនៅក្នុងក្រុងទេវទហៈ ហើយបង្កើតបានជាកោលិយវង្សជារៀងរហូតតមក ។

ក្នុងការដោះស្រាយបញ្ហានេះ មហានាមសាក្យៈ បានផ្តល់យោបល់ថា ខ្លួនមានភរិយាជាស្រីបំរើម្នាក់ មានបុត្រីឈ្មោះវាសភខត្តិយា គួរតែបញ្ជូននាងវាសភខត្តិយាទៅអោយព្រះបាទបសេនទិកោសល្យ ទើបមិនជាការធ្វើអោយអាប់អោនដល់សាក្យវង្ស ។ ទីប្រជុំបានយល់ស្របចំពោះយោបល់នេះ ទើបអោយគេបញ្ជូននាងវាសភខត្តិយាអោយទៅអភិសេកជាមហេសីរបស់ព្រះបាទបសេនទិកោសល្យ ដោយប្រាប់ថាជាធីតារបស់មហានាមសាក្យៈ ។

នាងវាសភខត្តិយា បាននៅរួមរស់ជាមួយព្រះបាទបសេនទិកោសល្យ ប្រសូតិបានបុត្រម្នាក់ឈ្មោះវិឌូឌភៈ ។ ពេលដែលវិឌូឌភៈមានវ័យវឌ្ឍនាការចំរើនឡើងក៏បានសិក្សាចប់នូវសិល្បិ៍សាស្ត្រវិជ្ជា ហើយបានទទួលតំណែងជាសេនាបតីនៃដែនកោសល្យ [១] ។ ក្នុងពេលដែលវិឌូឌភៈមានវ័យកំលោះ មានចិត្តចង់ទៅសួរសុខទុក្ខសាច់ញាតិខាងមាតា ទើបសុំអនុញ្ញាតនាងវាសភខត្តិយាដើម្បីធ្វើដំណើរទៅ ។ នាងក៏លួចផ្តល់ដំណឹងទៅក្រុងកបិលព័ស្តុអោយដឹងជាមុន ព្រោះក្នុងខ្សែភ្នែករបស់រាជវង្សសាក្យៈខាងក្រុងកបិលព័ស្តុនោះ វិឌូឌភៈគ្រាន់តែជាមនុស្សវណ្ណៈតូចទាប មិនគួរនឹងរួមទីអង្គុយ មិនគួររួមបរិភោគអាហារជាមួយគេទេ ។

---

១ កណ្ណកត្ថលសូត្រ មជ្ឈិមនិកាយ ភាគទី ១៣

អង្គប្រជុំដែលប្រកបដោយចិត្តកង្វល់ខ្វល់ខ្វាយបានកើតឡើងក្នុងក្រុងកបិលព័ស្តុម្តងទៀត ដើម្បីត្រៀមទទួលដំណើររបស់វិឌូឌុភៈ ឬនិយាយបានម្យ៉ាងទៀតថា ដើម្បីអោយមានបញ្ហាមិនពេញចិត្តកាន់តែតិច ។ អង្គប្រជុំសំរេចជាឯកច្ឆ័ន្ទថា បើអោយពួកមន្ត្រីដែលមានអាយុតិចជាងវិឌូឌុភៈនៅទទួលដែរ នឹងត្រូវសំពះវិឌូឌុភៈដែលជាហេតុនាំអោយអាប់អោនកិត្តិយស ។ គិតដូច្នោះហើយ ក៏រកមធ្យោបាយបញ្ជូនមន្ត្រីក្មេងៗជាងវិឌូឌុភៈទៅកាន់ជនបទអស់ សល់តែចាស់ៗដែលមានអាយុខ្ពស់ជាងវិឌូឌុភៈ គ្រាន់តែចាំទទួលការសំពះតែម៉្យាង ។

ពេលដែលវិឌូឌុភៈនិងបរិវារមកដល់ គេក៏ឃើញតែចាស់ៗ ដែលសុទ្ធតែមានអាយុច្រើនជាងខ្លួនទាំងអស់ ក៏ត្រូវសំពះគេគ្រប់ៗគ្នា ។ ការមកសួរសុខទុក្ខរបស់វិឌូឌុភៈនេះ មិនសូវជាបានផលប៉ុន្មានទេ ព្រោះផ្នែកអ្នកទទួលមិនសូវរាក់ទាក់ស្និទ្ធស្នាល គ្រាន់តែធ្វើទៅទាំងបង្ខំចិត្ត គឺទទួលសោះតែខាន ទាំងភាពសោះកក្រោះ មិនបានធ្វើដោយស្មោះអស់ពីចិត្តនោះទេ ទីបំផុតវិឌូឌុភៈក៏ធ្វើដំណើរត្រឡប់ទៅវិញ ។

លុះវិឌូឌុភៈចាកចេញទៅ ស្តេចសាក្យៈក៏ប្រមូលបាវព្រាវទាំងឡាយអោយយកទឹកដោះស្រស់មកលាងកន្លែងអង្គុយរបស់វិឌូឌុភៈដើម្បីបញ្ចៀបណ្តេញនូវចង្រៃឧបទ្រពចេញ ។ ពួកបាវព្រាវទាំងឡាយ លាងបណ្តើរជេរបណ្តើរថា មិនគួរអោយខ្លួនមកពិបាកក្នុងរឿងយ៉ាងនេះសោះ ហើយថែមទាំងជេរថា ជាកូនរបស់ទាសីទៀតផង ។

ថ្ងៃដន្យពេលនោះមនុស្សរបស់វិឌូឌុភៈបានភ្លេចរបស់ ហើយក៏ត្រឡប់មកយករបស់នោះត្រឡប់ទៅវិញ បរិវាររបស់វិឌូឌុភៈបានឃើញបានឮគ្រប់ហេតុការណ៍ទាំងអស់ ក៏យកដំណឹងនោះទៅប្រាប់វិឌូឌុភៈ ។ រឿងនោះបណ្តាលអោយវិឌូឌុភៈមានការឈឺចាប់នឹងចងគំនុំយ៉ាងខ្លាំងក្លា រហូតដល់វិឌូឌុភៈបញ្ចេញវាចាថា បើបានសោយរាជ្យជាស្តេចផែនដីពេលណា នឹងលើកទ័ពមកសំលាប់ពួកសាក្យអោយអស់ ហើយនឹងអារ ក យកឈាមលាងក្តារដែលធ្លាប់លាងដោយទឹកដោះគោស្រស់នោះអោយទាល់តែបាន ។

ក្រោយមកវិឌូឌុភៈក៏បានទទួលរាជសម្បត្តិសមចិត្តប្រាថ្នា ក៏លើកទ័ពមកដូចដែលបាននិយាយទុកពីមុន ប៉ុន្តែបានជួបព្រះសម្មាសម្ពុទ្ធតាមផ្លូវ ក៏នាំគ្នាលើកទ័ពត្រឡប់ទៅវិញដោយសេចក្តីគោរពកោតក្រែង ។ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះកាយស្ទាក់ផ្លូវវិឌូឌុភៈរហូតដល់បីដង ហើយវិឌូឌុភៈក៏លើកទ័ពត្រលប់ទៅវិញទាំងបីដង ។ លុះដល់លើកទី៤ ព្រះអង្គទ្រង់មិនបានយាងមកទេ ព្រោះទ្រង់យល់ថាជារឿងកម្មដែលមិនអាចមាននរណាដោះស្រាយជំនួសគ្នាបាន ។ វិឌូឌុភៈក៏លើកទ័ពទៅច្បាំង ចាប់ស្តេចសាក្យៈអារក ហើយយកឈាម

ដែលហូរចេញពីបំពង់ក ទៅលាងក្តារដែលស្តេចសាក្យៈធ្លាប់យកទឹកដោះគោស្រស់ទៅលាងនោះ បានដូចចិត្តប្រាថ្នា ។

ផលប៉ះទង្គិចដែលកើតឡើងដោយសារពតិមានស្តីពីស្តេចសាក្យៈបានលើកធីតាដែលកើតពីទាសី ឱ្យជាមហេសីនៃព្រះបាទបសេនទិកោសល្យក៏កើតមានឡើង ។ ពេលដែលព្រះបាទបសេនទិកោសល្យទ្រង់ជ្រាបមុនដំបូងព្រះអង្គទ្រង់ព្រះពិរោធដ៏ខ្លាំង ទ្រង់បញ្ជាអោយគេដកគ្រឿងរាជូបភោគផ្សេង១ ដែលធ្លាប់អោយដល់នាងវាសភខត្តិយា និង វិឌូឌភៈ ហើយអោយប្រើប្រាស់នូវគ្រឿងឧបភោគបរិភោគតាមបែបអ្នកបំរើវិញ ។

ក្រោយមកព្រះបាទបសេនទិកោសល្យក្រាបទូលរឿងនេះអោយព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាប ព្រះអង្គក៏ទ្រង់ត្រាស់ប្រាប់ថា ត្រកូលខាងបិតាសំខាន់ជាងខាងមាតា ដោយទ្រង់លើកយកប្រវត្តិព្រះបាទកដ្ឋវាហនៈដែលជាបុត្ររបស់ស្រីរកឧស តែស្រ្តីនោះបានជាមហេសីរបស់ព្រះរាជាក្រុងពារាណសី ។ ព្រះបាទកដ្ឋវាហនៈក៏បានសោយរាជ្យក្នុងក្រុងពារាណសី ជាព្រះមហាក្សត្រដ៏សំខាន់មួយអង្គតពង្សវង្សត្រកូលរហូតមក ។ បានស្តាប់ដូច្នោះហើយ ព្រះបាទបសេនទិកោសល្យក៏ទ្រង់ព្រះរាជទានគ្រឿងរាជូបភោគដល់នាងវាសភខត្តិយា និង វិឌូឌភៈឡើងវិញ ហើយការតែងតាំងវិឌូឌភៈអោយទទួលតំណែងជាសេនាបតីក៏ធ្វើឡើងក្នុងពេលក្រោយហេតុការណ៍នោះ ។

ភាពច្របូកច្របល់ដែលទាក់ទងទៅនឹងការប្រកាន់វណ្ណៈជាតិត្រកូល ដែលកើតមានចំពោះសាក្យវង្សនោះ គឺនៅក្នុងសម័យកាលដែលព្រះសម្មាសម្ពុទ្ធជិតចូលបរិនិព្វានទៅហើយ ។ ប្រសិនបើរាជវង្សសាក្យៈជឿត្រង់ត្រាប់ស្តាប់ប្រតិបត្តិតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធ កាត់បន្ថយនូវមានៈអោយថយចុះទៅខ្លះ ម្ល៉េះគង់នឹងមិនជួបប្រទះនូវវិនាសកម្មដល់ថ្នាក់នោះទេ ។

ដើម្បីបង្ហាញអោយច្បាស់ពីសាច់រឿងដែលបានរៀបរាប់មក សុំបញ្ជាក់បន្ថិចទៀតថា តាមឯកសារព្រះពុទ្ធសាសនាមានសំដែងថា អ្នកដែលមានវណ្ណៈផ្សេងគ្នានេះ មានវិជ្ជាពិសេសក្នុងរឿងជាតិវណ្ណៈរបស់ខ្លួនគ្រប់១គ្នា ។ វិជ្ជានេះជាវិជ្ជាសំងាត់ប្រចាំពូជពង្សវង្សត្រកូលរបស់ខ្លួន ដូចជាអ្នកកើតក្នុងត្រកូលក្សត្រ ពេលធ្លាក់ទៅក្នុងទីណាក្តី បើនឹងសំដែងខ្លួនជាក្សត្រ ជួនកាលក៏ត្រូវប្រើចំណេះដឹងដែលហៅថា ខត្តិយមាយា ឬហៅថា royal etiquette គឺពេលនិយាយគ្នាក្នុងចំណោមអ្នកត្រកូលក្សត្រដូចគ្នាក៏អាដឹងបានគ្រប់ពេលវេលា ។

ជួនកាល មានអ្នកកើតក្នុងត្រកូលចណ្ឌាលបានបន្លំខ្លួនធ្វើជាព្រាហ្មណ៍ រៀនសិល្បីសាស្ត្រវិជ្ជារួមជាមួយនឹងសិស្សដទៃ ហើយច្រឡំនិយាយភាសាសំងាត់របស់មនុស្សចណ្ឌាល ។ មិត្តភក្តិទាំងឡាយស្តាប់មិនយល់ក៏មានសេចក្តីសង្ស័យ លុះសឹបសាកសួរក៏ចាប់បានដឹងថា ជាមនុស្សវណ្ណៈទាបបន្លំខ្លួន[១] ។ រឿងមួយទៀតមានសំដែងក្នុងរឿងសាមាវតី ក្នុងអដ្ឋកថាធម្មបទ កន្លែងដែលមាតាព្រះបាទឧទេនសួរតាបសដែលជាក្សត្រចេញបួស ។ នាងនៅលើមែកឈើ តាបសនឹងទទួលនាងអោយចុះមក នាងមិនព្រមអោយតាបសប៉ះពាល់ខ្លួន លុះជ្រាបថាតាបសជាមនុស្សត្រកូលក្សត្រទើបព្រមអោយនាំចុះមក ។

ទាំងនេះគឺជាការបញ្ជាក់ពីការប្រើប្រាស់ភាសា ឬចំណេះដឹងពិសេសប្រចាំត្រកូល វណ្ណៈនីមួយៗ ដែលមានក្នុងប្រទេសឥណ្ឌាក្នុងសម័យមុន ។

## គោលធម៌ដែលទ្រង់ប្រដៅអោយឈប់ប្រកាន់វណ្ណៈ

១-ក្នុងសុន្ទរិកសូត្រ[២] ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឆ្លើយនូវសំនួររបស់សុន្ទរិកភារទ្វាជព្រាហ្មណ៍ ដែលសួរព្រះអង្គថា មានជាតិជាអ្វី? ព្រះអង្គទ្រង់ឆ្លើយថា កុំសួរពីជាតិធ្វើអ្វី ចូរសួរពីការប្រព្រឹត្តវិញទើបប្រសើរដូចដែលបានលើកមកពីខាងដើមរួចហើយ ។ ក្នុងលំដាប់តទៅព្រះអង្គទ្រង់សំដែងគោលធម៌ និង ហេតុផលថា

**"ភ្លើងរមែងកើតពីឈើ (គ្រប់ប្រភេទ) បណ្ឌិតសូម្បីកើតក្នុងត្រកូលទាប តែជាអ្នកមានសេចក្តីព្យាយាម ជាអ្នកវៀរចាកអំពើអាក្រក់ដោយសេចក្តីខ្មាស់បាប មានសច្ចៈ មានខ្លួនអប់រំល្អហើយក៏អាចជាមនុស្សអាជានេយ្យបាន "** ។

២-ក្នុងសីលវីមំសជាតក[៣] បានចារឹកនូវគោលធម៌ប្រៀបធៀប រវាងសីលនិងវណ្ណៈ ដោយសំដែងភាសិតរបស់ព្រាហ្មណ៍ម្នាក់ថា

---

១ អដ្ឋកថា ចិត្តសម្ភូតជាតក វីសតិនិបាត ភាគ ៧

២ សំយុត្តនិកាយ សគាថវគ្គ ភាគទី ១៥

៣ សុត្តន្តបិដក ភាគ ២៧ បញ្ចកនិបាត

"ខ្ញុំមានសេចក្តីសង្ស័យថា សីល (ការប្រព្រឹត្តកាយវាចាអោយមានរបៀបរៀបរយ) ប្រសើរជាង ឬ សុត្តៈ (ចំណេះដឹងដែលកើតឡើងពីការរៀនការស្តាប់ ) ប្រសើរជាង? ហើយខ្ញុំក៏អស់នូវក្តីសង្ស័យដោយយល់ឃើញថា សីលប្រសើរជាងសុតៈ។

"ជាតិនិងវណ្ណៈជារបស់សូន្យធេង សីលទេតើជារបស់ខ្ពង់ខ្ពស់ បើមិនមានសីលទេ សុតៈក៏នឹងគ្មានប្រយោជន៍អ្វីទាល់តែសោះ ។

"កើតជាក្សត្រតែមិនតាំងនៅក្នុងធម៌ កើតជាឈ្មួញតែមិនអាស្រ័យធម៌ ជនទាំងនោះរមែងលះលោកទាំងពីរ (គឺទេវលោក និង មនុស្សលោក) ចូលទៅកាន់ទុគ្គតិ ។

"ក្សត្រ ព្រាហ្មណ៍ វេស្សៈ សូទ្រៈ មនុស្សចណ្ឌាល អ្នកដុតខ្មោច ឬអ្នកបំរើដែលលាងបង្គន់ក្តីប្រព្រឹត្តធម៌ក្នុងលោកនេះហើយ រមែងស្មើគ្នាក្នុងត្រៃទិព្វ (គឺក្នុងទេវលោកឬពោលតាមគោលធម៌ជនទាំងនេះឈ្មោះថា មានគុណធម៌របស់ទេវតាស្មើគ្នា )។

"ព្រះវេទក្តី ជាតិត្រកូលក្តី បក្សពួកក្តី មិនមែនជាមិត្តក្នុងសម្បរាយភព(១)ទេ សីលដ៏បរិសុទ្ធរបស់ខ្លួនវិញទេ ដែលនាំសេចក្តីសុខមកអោយក្នុងសម្បរាយភព (ភពខាងមុខ)។

៣-ក្នុងកណ្ណកត្ថលសូត្រ[២] ព្រះសម្មសម្ពុទ្ធទ្រង់សំដែងថា "វណ្ណៈទាំង ៤ គឺក្សត្រ ព្រាហ្មណ៍ វេស្សៈ និង សូទ្រៈ បើមានគុណធម៌ក្នុងខ្លួនហើយក៏ឈ្មោះថា ស្មើគ្នា ។ ព្រះអង្គទ្រង់ប្រៀបធៀបថា បើនាំយកដើមសាលព្រឹក្ស ដើមស្វាយ ដើមល្វាដែលស្ងួតមកដុត ផលគឺ អណ្តាតភ្លើង ពណ៌របស់ភ្លើង និងពន្លឺភ្លើងដែលកើតឡើង ក៏គ្មានអ្វីប្លែកគ្នា ។ "

៤-នៅក្នុងអគ្គញ្ញសូត្រ[៣] ព្រះភគវាទ្រង់ត្រាស់នឹងវាសេដ្ឋៈ និង ភារទ្វាជព្រាហ្មណ៍ ទ្រង់បញ្ជាក់យ៉ាងប្រត្យក្សថា រឿងដែលពួកព្រាហ្មណ៍ លើកតំកើងវណ្ណៈរបស់ខ្លួនថា មានតែវណ្ណៈព្រាហ្មណ៍ប៉ុណ្ណោះជាវណ្ណៈស ពួកវណ្ណៈដទៃទៀតជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ជាអ្នកបរិសុទ្ធ ពួកដទៃទៀតមិនបរិសុទ្ធនោះ ព្រោះមិនបានរលឹកដល់រឿងចាស់ ។ តាមពិត ដែលពួកព្រាហ្មណ៍និយាយថា ខ្លួនកើតអំពីមាត់ព្រហ្ម ជាឱរសរបស់ព្រះព្រហ្មនោះមិនពិតទេ ព្រោះព្រាហ្មណ៍គ្រប់គ្នាក៏កើតមកពីមាតាដែលជា

---

១ ភពខាងមុខ បរលោក។ ២ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ សុត្តន្តបិដក ភាគ ១៣ ។ ៣ ទីឃនិកាយ បាដិកវគ្គ សុត្តន្តបិដក ភាគ ១១ ។

ព្រាហ្មណី ត្រូវតាំងគភ៌ ប្រសូតិចាកគភ៌ ត្រូវបៅទឹកដោះម្តាយដូចគ្នា គ្មានអ្វីវិសេសវិសាលជាង អ្នកដទៃទាល់តែសោះ ។

មនុស្សគ្រប់គ្នា មិនថាកើតក្នុងវណ្ណៈណាទេ អាចធ្វើនូវអកុសលកម្មបទ គឺ ទុច្ចរិតដោយ កាយ វាចា ចិត្តបានដូចគ្នា អាចវៀរចាកនូវអកុសលកម្មបទ គឺប្រព្រឹត្តសុចរិតដោយ កាយ វាចា ចិត្ត បានដូចគ្នា ។

ហើយព្រះអង្គក៏ទ្រង់សំដែងរឿងរ៉ាវពីអតីតកាល ដែលជាហេតុនៃការបែងចែកវណ្ណៈ ថា

រឿងហេតុទាំងនោះមកពីការបែងចែកទៅតាមតួនាទី ដែលតាមភាសាសេដ្ឋកិច្ចហៅថា Division of labour ពោលគឺនរណាមានតួនាទីអ្វី ក៏បែងចែកប្រភេទទៅតាមនោះ ។ លុះចំណេរ កាលក្រោយមកក៏នាំគ្នាយល់ខុស ប្រកាន់យកជាហេតុនៃការប្រមាថមើលងាយគ្នា ។ ទីបំផុតព្រះអង្គ ទ្រង់សរុបថា "ម្នាលវាសេដ្ឋៈ និង ភារទ្វាជៈ ធម្មៈជារបស់ប្រសើរបំផុតក្នុងពពួកមនុស្ស ទាំងក្នុង បច្ចុប្បន្ននិងអនាគត។"

៥-ក្នុងមធុរសូត្រ[១] សំដែងពីការចោទឆ្លើយរវាងព្រះមហាកច្ចាយនត្ថេរ ព្រះអរហន្តសាវ័កដែលព្រះ សម្មាសម្ពុទ្ធទ្រង់លើកតំកើងជាឯតទគ្គៈ[២] ខាងឆ្លាតវៃក្នុងការអធិប្បាយសេចក្តីសង្ខេបអោយទៅជាពិស្តារ ជាមួយព្រះបាទមធុររាជអវន្តីបុត្រដែលទៅសួរព្រះថេរៈពីមតិរបស់ព្រាហ្មណ៍ក្នុងរឿងវណ្ណៈ ដែលថាមានតែ ព្រាហ្មណ៍ប៉ុណ្ណោះជាអ្នកប្រសើរ ។ ព្រះថេរៈបានសំដែងហេតុផលជាសេចក្តីខ្លី៧ដូចតទៅនេះ :-

១.ក្នុងវណ្ណៈទាំង ៤នេះ វណ្ណៈទាំងឡាយណាជាអ្នកស្តុកស្តម្ភ វណ្ណៈដូចគ្នានិងវណ្ណៈដទៃ រមែង ចូលជាសាវ័ករបស់វណ្ណៈនោះ ។

២.វណ្ណៈណាប្រព្រឹត្តនូវអកុសលកម្មបទ ពេលស្លាប់ទៅ រមែងចូលកាន់អបាយភូមិទាំងបួន ណាមួយស្មើគ្នាទាំងអស់ គ្មាននរណាជាអ្នកពិសេសឡើយ។

៣.វណ្ណៈណាប្រព្រឹត្តកុសលកម្មបទ ពេលស្លាប់ទៅ រមែងចូលទៅកាន់សុគតិសួគ៌ទេវលោក ដូចគ្នាទាំងអស់ មិនមានវៀរលែងឡើយ ។

---

១ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ សុត្តន្តបិដកភាគ ១៣ ។ ២ ជាកំពូល ជាឯក

**៤.វណ្ណៈណាប្រព្រឹត្តចោរកម្ម ធ្វើនូវបរទារកម្ម (ការប្រព្រឹត្តកន្លងលើភរិយាអ្នកដទៃ) វណ្ណៈនោះត្រូវតែទទួលរាជអាជ្ញាដូចគ្នាទាំងអស់គ្មានលើកលែង ។**

**៥.វណ្ណៈណាចេញបួស តាំងនៅក្នុងសីល ក្នុងធម៌ វណ្ណៈនោះរមែងបានទទួលការគោរព រាប់អាន បានទទួលការទំនុកបំរុងនិងបានទទួលការគ្រប់គ្រងរក្សាស្មើគ្នាទាំងអស់មិនមានលើកលែង។**

ព្រះបាទមធុរាជ ត្រាស់សរសើរភាសិតរបស់ព្រះមហាថេរៈ ហើយប្តេជ្ញាព្រះអង្គជាពុទ្ធសាសនិកជន តែពេលនោះព្រះបរមសាស្តាទ្រង់ចូលបរិនិព្វានផុតទៅហើយ ទើបទ្រង់ត្រាស់ថា បើព្រះអង្គដឹងថា ព្រះភគវាទ្រង់ប្រថាប់ក្នុងទីណា ទោះជាឆ្ងាយប៉ុណ្ណាក៏ដោយក៏ព្រះអង្គនឹងយាងទៅគាល់អោយទាល់តែបាន ។ ព្រះដ៏មានព្រះភាគទ្រង់បរិនិព្វានផុតទៅហើយ ព្រះអង្គសូមដល់ព្រះដ៏មានព្រះភាគដែលទ្រង់បរិនិព្វានហើយ ព្រមទាំងព្រះធម៌និងព្រះសង្ឃជាសរណៈ គឺជាទីពឹងទីរលឹក ។

តាមប្រវត្តិនិងគោលធម៌ដែលបានពោលមកនេះ អាចអោយយើងឃើញជាក់ច្បាស់ថា ព្រះសម្មាសម្ពុទ្ធទ្រង់តស៊ូជំនះនិងបំបាត់នូវទិដ្ឋិមានៈក្នុងការបែងចែកវណ្ណៈរបស់មនុស្សក្នុងជំនាន់នោះប៉ុណ្ណា។ ទ្រង់ព្យាយាមបង្ហាត់បង្រៀនប្រៀនប្រដៅអោយមនុស្សសំលឹងឃើញ នូវសារៈសំខាន់នៃការប្រព្រឹត្តប្រតិបត្តិតាមសីលធម៌ថា មានគុណតំលៃជាងការជាប់ជំពាក់ក្នុងរឿងវណ្ណៈ ជាតិ ត្រកូល ព្រមទាំងបានទ្រង់ធ្វើជាគំរូដ៏ប្រពៃក្នុង ព្រះធម្មវិន័យនេះ គឺ នរណាមកបួសមុនក៏បានទទួលនូវសេចក្តីគោរពរបស់អ្នកមកបួសក្រោយទោះជាកើតក្នុងត្រកូលខ្ពស់ជាងក៏ដោយ ។

ក្នុងសម័យបច្ចុប្បន្ន ប្រទេសឥណ្ឌាបានប្រើប្រាស់រដ្ឋធម្មនុញ្ញ ដែលផ្តល់សិទ្ធិអោយប្រជាជនគ្រប់រូបមានវណ្ណៈស្មើគ្នា និងមានមនុស្សដែលត្រូវគេប្រមាថមើលងាយព្រោះហេតុតែកើតក្នុងវណ្ណៈទាបរាប់សែននាក់ សុំប្តេជ្ញាខ្លួនជាពុទ្ធសាសនិកជន (ព.ស ២៤៩៩) ព្រោះសេចក្តីជ្រះថ្លាដែលថា ព្រះពុទ្ធសាសនាជាសាសនាដែលមិនមើលរំលងមនុស្សវណ្ណៈដែលត្រូវគេប្រមាថមើលងាយ ។ មិនតែប៉ុណ្ណោះ ព្រះអង្គថែមទាំងជួយលើកឋានៈឡើង អោយខ្ពស់ស្មើនឹងវណ្ណៈដទៃទាំងដែលព្រះអង្គទ្រង់កើតក្នុងវណ្ណៈក្សត្រ មិនមានចំណុចខ្សោយ ឬការឈឺចាប់ណាមួយដែលនឹងត្រូវតស៊ូដើម្បីព្រះអង្គផ្ទាល់ឡើយ តែទ្រង់ខិតខំត្រាស់បង្រៀនប្រៀនប្រដៅអោយមនុស្សឃើញនូវសច្ចធម៌តាំងពីសម័យព្រះអង្គរហូតមក។

នៅក្នុងសុន្ទរកថាផ្សេងៗរបស់មេដឹកនាំប្រទេសឥណ្ឌា តែងតែពោលសរសើរព្រះសម្ពុទ្ធជានិច្ចថា **ព្រះសម្មាសម្ពុទ្ធទ្រង់ប្រទាននូវពន្លឺដល់ប្រទេសឥណ្ឌាអស់រយៈពេលជាយូរមកហើយ ពីរឿងការបែងចែកវណ្ណៈ** តែឥណ្ឌាទើបតែប្រតិបត្តិបានតាមនីតិន័យក្នុងពេលដែលមានរដ្ឋធម្មនុញ្ញនេះឯង ចំណែកខាងការប្រតិបត្តិនោះ នរណាទៅដឹងថា ពេលណាទើបឥណ្ឌាអាចជំរះលាងនូវសេចក្តីប្រកាន់បែបចាស់គំរិលនេះអោយអស់បាន... ។

ពិភពលោករឹតតែលើកតំកើងសមភាព និង ភាតរភាពក្នុងសង្គមមនុស្សខ្លាំងប៉ុណ្ណា គោលធមិទាក់ទងនឹងរឿងនេះរបស់ព្រះពុទ្ធសាសនារឹតតែលេចធ្លោរក្នុងខ្សែភ្នែកអ្នកដែលត្រូវការហេតុផលកាន់តែខ្លាំងឡើង។

វណ្ណៈសក្តិយសកើ្តឈ្មោះបវរ កើតពីសីលធមិប្រចាំចិត្តកាយ
គិតល្អធ្វើល្អគ្មានល្បិចគេចឆ្ងាយ ចរចាបរិយាយស្រស់ស្រាយពីរោះ ។
ឫកពាទន់ភ្លន់ទើបគន់ថ្លៃថ្នូរ ចរិយាសម្បូរបវរខ្ពង់ខ្ពស់
ផ្តល់សក្តិអោយគេៗគង់អោយយស ជំទើតអើតខ្ពស់គង់បះជើងផ្ទារ ។
ជំទយលយឿនមិនគិតមុខក្រោយ ខ្លាំងមិនដែលខ្សោយស្រវឹងអាត្មា
ត្រូវមិនដែលខុសនឹកគួរអនិច្ចា យ៉ាងនេះលោកថាចិន្តាមានះ ។
ល្អះល្អបរិសុទ្ធគឺព្រះអរហន្ត ជាតិបុថុជ្ជនកំហុសពោរពាស
មើលខ្លួនមិនខុសជារឿងគួរចៀស ខ្លួនខុសរូតរះកែកុំធ្វើហី ។
អ្នកឃើញគេខុសមានពេញនគរ អណ្តាតបន្ទរិះគន់ហារស្តី
អ្នកឃើញខ្លួនខុសនោះសែនក្រក្រី បើមានលោកស្តីថាល្អកន្លង ។
ទិដ្ឋិ មានៈ ទោសៈ មោហា ពង្វក់ចិន្តាអោយលង់សៅហ្មង
ជាព្រាយបិសាចកោងកាចទាក់ចង ចូលធ្លាក់ចំណោងវណ្ណៈសក្តិយស ។
កើតមកជាមនុស្សរស់លើពសុធា ចង់សុខដូចគ្នាចង់បានខ្ពង់ខ្ពស់
នៅក្នុងសង្គមចង់ល្អឥតមោះ ហេតុនេះគួររស់ចេះស្រលាញ់គ្នា ។

ថ្ងៃទី ០១ ខែ កញ្ញា ព.ស ២៥៥០ គ.ស ២០០៦